# ជំពូកទី ៣

# ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ

## គោលបំណងមេរៀន

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពីៈ

- គោលការណ៍នៃការលូតលាស់ និងការអភិវឌ្ឍ
- លក្ខណៈនៃការលូតលាស់ និងការអភិវឌ្ឍកាយសម្បទា និងមុខងារសរីរាង្គរបស់កុមារចាប់តាំងពីទារកភាពរហូតដល់ដើមវ័យជំទង់
- អ្វីដែលចាំបាច់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារឱ្យមានសុខភាពល្អស្របតាមស្ថានភាពនៅប្រទេសកម្ពុជា

ជំពូកនេះបង្ហាញអំពីបញ្ញត្តិនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ បន្ទាប់មកពិពណ៌នាអំពីគោលការណ៍ទូទៅនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ និងពន្យល់អំពីលក្ខណៈនៃការលូតលាស់ និងការអភិវឌ្ឍកាយសម្បទា និងផ្លូវចិត្តរបស់កុមារចាប់តាំងពីទារកភាពរហូតដល់ដើមវ័យជំទង់។ ចុងក្រោយ យើងនឹងពិពណ៌នាអំពីកត្តានានាដែលប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍ។

## ១ ការអភិវឌ្ឍរបស់មនុស្ស

ដំណើរការនៃភាពចាស់ទុំរបស់មនុស្សចាប់តាំងកំណើតរហូតដល់ពេញវ័យត្រូវបានបង្ហាញឱ្យស្គាល់តាមពាក្យផ្សេងៗជាច្រើនដូចជា «**ការលូតលាស់ (growth)**» «**ការអភិវឌ្ឍ (development)**» និង «**ភាពចាស់ទុំ (maturity)**»។ ការលូតលាស់សំដៅលើដំណើរការនៃភាពចាស់ទុំរបស់សរីរាង្គមានជីវិតដោយបង្កើនបរិមាណតាមរយៈការបំបែកកោសិកា ឬនិយាយម្យ៉ាងទៀតថាជា**ការប្រែប្រួលផ្នែកបរិមាណរូបសាស្ត្រ (Quantitative change in morphology)** ឬការលូតលាស់កាយសម្បទា។ ទម្ងន់ និងកម្ពស់រាងកាយគឺជាសូចនាករតំណាងឱ្យការលូតលាស់។ ចំណែកឯការអភិវឌ្ឍវិញ វាជាដំណើរការមួយដែលរចនាសម្ព័ន្ធ និងមុខងារជីវសាស្ត្រឆ្លងកាត់ការបំបែក និងការប្រែប្រួលនានាឱ្យកាន់តែមានភាពសាំញ៉ាំ។ តាមរយៈដំណើរការនេះ មុខងារនានាដែលសម្ងំនឹងលេចឡើងទៅតាមពេលវេលា។ វាជាបាតុភូតនៃ**ការប្រែប្រួលផ្នែកគុណវិស័យ (Qualitative change)** ដែលបានទទួលឥទ្ធិពលបន្ថែមពីបទពិសោធន៍ ការអនុវត្ត ការបណ្តុះបណ្តាល ការអប់រំ និងបរិស្ថានជុំវិញ។ និយាយម្យ៉ាងទៀត ការអភិវឌ្ឍសំដៅលើការលូតលាស់នៃរចនាសម្ព័ន្ធ និងមុខងារដែលផ្តោតសំខាន់ទៅលើផ្នែកគំនិតបញ្ញា។[1]

កុមារនៅតែស្ថិតក្នុងដំណើរនៃការលូតលាស់និងការអភិវឌ្ឍ។ ចិត្ត កាយសម្បទា និងទំនាក់ទំនងសង្គមរបស់ពួកគេប្រែប្រួលជារៀងរាល់ថ្ងៃឆ្ពោះទៅកាន់ភាពចាស់ទុំ។ វាពិតជាសំខាន់ណាស់ សម្រាប់កុមារក្នុងការមានកុមារភាពប្រកបដោយសុខភាពល្អដើម្បីអភិវឌ្ឍសមត្ថភាពខាងបញ្ញា កាយសម្បទា និងសតិអារម្មណ៍ឱ្យមានសក្តានុពលភាពពេញលេញ។

ការលូតលាស់ និងការអភិវឌ្ឍប្រកបដោយសុខភាពល្អរបស់កុមារមិនត្រឹមតែធ្វើឱ្យកាន់តែប្រសើរឡើងក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេប៉ុណ្ណោះទេ តែថែមទាំងសង្គមទាំងមូលផងដែរ។ ដោយសារតែកុមារចំណាយពេលភាគច្រើននៅសាលារៀន គ្រូបង្រៀនដែលនៅផ្ទាល់ជាមួយកុមារមានកាតព្វកិច្ចជួយគាំទ្រការលូតលាស់ និងការអភិវឌ្ឍរបស់កុមារប្រកបដោយសុខភាពល្អ។ សរុបសេចក្តីមក វាជាការសំខាន់ដែលគ្រូបង្រៀនទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវចំណុចទាំងបួនខាងក្រោម និង**សម្លឹងមើលលើទិដ្ឋភាពរួមនៃសន្តនិយមសុខភាពកុមារម្នាក់ៗ** ជាជាងការសម្លឹងមើលតែទិដ្ឋភាពមួយជ្រុងនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។[2]

i. ចាត់ទុកកុមារជាបុគ្គលមួយពេញលក្ខណៈ។ ស្វែងយល់ពីចរិតលក្ខណៈដោយឡែករបស់កុមារម្នាក់ៗ និងប្រើប្រាស់វិធីសាស្រ្តចម្រុះដើម្បីវាយតម្លៃសុខភាពរបស់ពួកគេ។
ii. ជឿជាក់លើសមត្ថភាពធម្មជាតិដើម្បីលូតលាស់ដែលកុមារម្នាក់ៗមានតាំងពីកំណើត។ ទទួលស្គាល់ថា កុមារគ្រប់រូបមានភាពស្វាហាប់ខ្លាំងរៀងៗខ្លួន។
iii. ស្វែងយល់ ជឿជាក់ និងជួយអភិវឌ្ឍសមត្ថភាពពីកំណើតរបស់កុមារម្នាក់ៗ។ ទារកទើបកើតមានសមត្ថភាពផ្សេងៗតាំងពីកំណើតរួចមកហើយ។ យើងត្រូវជឿជាក់លើសមត្ថភាពទាំងនោះ និងជួយគាំទ្រដើម្បីបំពេញសក្តានុពលរបស់ពួកគេ។
iv. ពិនិត្យមើលទិដ្ឋភាពដំណើរជីវិតរបស់កុមារដើម្បីជួយគាំទ្រអនាគតរបស់ពួកគេ។ ទិដ្ឋភាពដំណើរជីវិតរបស់កុមារពាក់ព័ន្ធនឹងការយល់អំពីសុខភាពកុមារដោយផ្អែកលើអតីតកាល បច្ចុប្បន្ន និងអនាគតរបស់ពួកគេ។ យើងក៏ត្រូវកំណត់ទុកក្នុងចិត្តផងដែរថា លក្ខខណ្ឌផលប៉ះពាល់សុខភាពកាលពីកុមារភាពអាចនឹងមិនបង្ហាញចេញជារូបរាងលុះត្រាពេញវ័យ។

គ្រូបង្រៀនអាចបង្ហាត់បង្រៀនកុមារទៅតាមដំណាក់កាលនៃការលូតលាស់និងការអភិវឌ្ឍរបស់ពួកគេតាមរយៈការសិក្សាអំពីដំណើរលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។ គ្រូបង្រៀនក៏អាចជួយក្នុងការបង្កើតនូវបរិស្ថានដែលលើកកម្ពស់ដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារប្រកបដោយសុខភាពល្អតាមរយៈការលុបបំបាត់នូវកត្តានានាដែលមានផលប៉ះពាល់មិនចង់បាន ហើយតាមរយៈការណែនាំកុមារព្រមទាំងគ្រួសាររបស់ពួកគេឱ្យចៀសវាងកត្តាទាំងនោះ។ លើសពីនេះទៅទៀត តាមរយៈការសិក្សាពីលំនាំទូទៅនៃការលូតលាស់ និងការអភិវឌ្ឍ គ្រូបង្រៀនអាចវាយតម្លៃបានថា តើកុមារកំពុងអភិវឌ្ឍសមស្របក្នុងកម្រិតធម្មតាដែរឬទេ និងជួយចាប់ផ្តើមដោះស្រាយរាល់បញ្ហាតាំងពីដំណាក់កាលដំបូងប្រសិនបើមានភាពមិនប្រក្រតី ឬសង្ស័យថាមានបញ្ហាណាមួយកើតឡើង។

## ២ គោលការណ៍នៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ

ការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្សត្រូវបានគេចាត់ទុកថាជាលទ្ធផលនៃការសំយោគរវាងដំណើរនៃភាពចាស់ទុំផ្នែកជីវសាស្រ្តដែលកំណត់ដោយសែន និងដំណើរអភិវឌ្ឍន៍ដែលទទួលឥទ្ធិពលពីបរិស្ថាន និងបទពិសោធន៍សិក្សារបស់បុគ្គលម្នាក់ៗ។ **ភាពខុសគ្នារបស់បុគ្គលម្នាក់ៗ**ក្នុងការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្សបណ្តាលមកពីភាពខុសគ្នានៃដំណើរនៃភាពចាស់ទុំផ្នែកជីវសាស្រ្ត និងដំណើរអភិវឌ្ឍន៍ដែលរងឥទ្ធិពលពីបរិស្ថានជុំវិញ។ ទោះជាយ៉ាងណាក៏ដោយ វាមានគោលការណ៍រួមនៃការលូតលាស់ និងការអភិវឌ្ឍដែលកើតមានជាទូទៅចំពោះបុគ្គលភាគច្រើន។

### ២.១. កុមារភាគច្រើនមានការអភិវឌ្ឍទៅតាមលំដាប់លំដោយមួយជាក់លាក់

ការលូតលាស់កាយសម្បទា និងការអភិវឌ្ឍមុខងារចលករប្រព្រឹត្តទៅតាមលំដាប់លំដោយមួយជាក់លាក់។ ឧទាហរណ៍ កុមារភាគច្រើនអាចងើបក្បាលឡើងបាននៅអាយុចន្លោះពី ៣-៤ខែ អាចក្រឡាប់បាននៅអាយុចន្លោះពី ៥-៦ខែ អាចអង្គុយដោយខ្លួនឯងបាននៅអាយុចន្លោះពី ៧-៨ខែ ចាប់ផ្តើមវារ និងឈរតោងគ្រឿងសង្ហារិមបាននៅអាយុចន្លោះពី ៩-១០ខែ ហើយនៅពេលចូលដល់អាយុ ១១ខែ កុមារខ្លះចាប់ផ្តើមដើរដោយខ្លួនឯងបាន។ ទោះបីជាមានភាពផ្សេងៗគ្នាច្រើននៅពេលដែលកុមារឈានដល់ដំណាក់កាលនៃការអភិវឌ្ឍមុខងារចលករក៏ដោយ ក៏កុមារភាគច្រើនមានការអភិវឌ្ឍទៅតាមលំដាប់លំដោយជាក់លាក់ដែរ (**រូបទី ៣.១**)។




**រូបទី ៣.១៖** ដំណាក់កាលនៃការលូតលាស់ និងការអភិវឌ្ឍរបស់ទារក

## ២.២. ទិសដៅជាក់លាក់ត្រូវបានសង្កេតឃើញក្នុងការលូតលាស់ និងការអភិវឌ្ឍ[3,4]

ការលូតលាស់កាយសម្បទា និងការអភិវឌ្ឍមុខងារចលករវិវឌ្ឍទៅតាមទិសដៅមួយជាក់លាក់។ ឧទាហរណ៍ ជំនាញចលករវិវឌ្ឍពីងើបក្បាល ក្រឡាប់ អង្គុយដោយខ្លួនឯងបន្ទាប់មកតោងឈរដោយខ្លួនឯង។ ដូចបានឃើញក្នុងលំដាប់លំដោយនេះ មុខងាររាងកាយអភិវឌ្ឍតាមទិសដៅពីក្បាលមកកន្ទុយ (cephalocaudal direction) និងមជ្ឈដ្ឋាន ឬចំណុចកណ្ដាលនៃដងខ្លួនមកកាន់ផ្នែកខាងៗ (proximodistal direction)។ នៅពេលយើងក្រឡេកមើលពីដំណើរចាប់កាន់វត្ថុអ្វីមួយរបស់កុមារ ដំបូងពួកគេចាប់ស្ទាបវត្ថុនោះជាមុនសិន រួចចាប់ផ្ដើមចាប់កាន់វត្ថុនោះដោយប្រើម្រាមដៃ និងបាតដៃ (palmar grasp) និងចុងក្រោយអាចចាប់កាន់ ឬលើកវត្ថុនោះឡើងដោយប្រើម្រាមដៃរបស់ពួកគេ (pincer grasp) (ពីសាមញ្ញទៅស៊ាំញ៉ាំ ពីទូទៅទៅជាក់លាក់)។ ដូចដែលបានឃើញនៅក្នុងរូបខាងក្រោម មុខងាររាងកាយអភិវឌ្ឍក្នុងទិសដៅពីមុខងារចលករធំទៅមុខងារចលកតូច (**រូបទី ៣.២**)។




**រូបទី ៣.២៖** ទិសដៅនៃការលូតលាស់ និងការអភិវឌ្ឍរាងកាយ

## ២.៣. និរន្តរភាពនៃការលូតលាស់និងការអភិវឌ្ឍ និងភាពខុសគ្នានៃល្បឿនលូតលាស់របស់សរីរាង្គ និងជាលិកា

ដូចបានឃើញនៅក្នុង**ខ្សែកោងនៃការលូតលាស់របស់លោកស្កេមម៉ុន (Scammon)** (ឆ្នាំ១៩៣០) ដែលបង្ហាញពីការលូតលាស់នៃជាលិកាជាច្រើនប្រភេទទៅតាមពេលវេលា ទោះបីជាមានការឡើងចុះនៃខ្សែកោងក៏ដោយក៏ការលូតលាស់ និងការអភិវឌ្ឍរបស់សរីរាង្គ និងជាលិកានៅតែបន្តលូតលាស់ដោយគ្មានការរំខានរហូតឈានដល់ទំហំកម្រិតមនុស្សពេញវ័យ បង្ហាញដោយ ១០០% (ដំណើរការនិរន្តភាព (Continuous process))។ ទោះជាយ៉ាងណា

ល្បឿននៃការលូតលាស់មានភាពខុសគ្នាអាស្រ័យទៅតាម អាយុ ភេទ និងមុខងាររបស់ជាលិកា (**កត្តាតំណពូជ**)។ ឧទាហរណ៍ កម្ពស់រាងកាយលូតខ្ពស់ចាប់ពីទារកភាពរហូតដល់វ័យជំទង់។ លើសពីនេះទៅទៀត អំឡុងពេលដែលកម្ពស់រាងកាយស្ទុះលូតមានភាពខុសគ្នារវាងក្មេងប្រុស និងក្មេងស្រី។ ជាលិកាប្រសាទអភិវឌ្ឍយ៉ាងលឿនក្នុងអំឡុងពេលទារកភាពនិងដើមកុមារភាព ខណៈជាលិកាឡាំហ្វាទិក (lymphoid tissue) អភិវឌ្ឍនៅពាក់កណ្តាល និងចុងកុមារភាព។ ទោះជាយ៉ាងណា គួរកត់សម្គាល់ថា ខ្សែកោងនៃការលូតលាស់របស់លោកស្កេមម៉ុន (Scammon) គ្រាន់តែបង្ហាញអំពីរូបភាពនៃការលូតលាស់ និងការអភិវឌ្ឍបន្ទាប់ពីកំណើតហើយតែប៉ុណ្ណោះ ហើយគួសម្គាល់ដែលថា ទំហំ និងមុខងារនៃសរីរាង្គ និងជាលិកានីមួយៗមិនស្មើសូន្យនោះទេនៅពេលកំណើត ចូរធ្វើលំហាត់លេខ [៣-៣] ទាំងអស់គ្នា។

## ២.៤. វាមានអំឡុងពេលសំខាន់ និងអំឡុងពេលវេទនារម្មណ៍ក្នុងដំណើរការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ[5]

ក្នុងដំណើរជីវសាស្ត្រនៃការលូតលាស់ និងការអភិវឌ្ឍមានអំឡុងពេលសំខាន់សម្រាប់អភិវឌ្ឍជំនាញកាយសម្បទា និងបញ្ញា ហើយនិងការទទួលយកលំនាំអាកប្បកិរិយាថ្មីៗ។ ប្រសិនបើក្មេងមិនទទួលបានការរំញោចពីបរិស្ថានសមស្រប ឬទទួលបទពិសោធន៍ដែលផ្តល់នូវជំនាញអំឡុងពេលនោះទេ វានឹងពិបាកសម្រាប់កុមារដើម្បីអភិវឌ្ឍមុខងារ ឬអាកប្បកិរិយាពាក់ព័ន្ធនានានៅពេលក្រោយក្នុងជីវិត។ អំឡុងពេលនេះហៅថា **អំឡុងពេលសំខាន់ (critical period)**។ ឧទាហរណ៍ នៅក្នុងករណីការអភិវឌ្ឍនៃញាណ និងចលករបរិស្ថាននិងបទពិសោធន៍នៅអំឡុងពេលទារកភាពបានជះឥទ្ធិពលយ៉ាងខ្លាំងលើការអភិវឌ្ឍគំហើញនៃភ្នែកទាំងពីរ (សមត្ថភាពមើលឃើញវត្ថុដោយប្រើភ្នែកទាំងពីរ) និងសមត្ថភាពស្តាប់ឮ។ នៅអំឡុងពេលសំខាន់សម្រាប់សមត្ថភាពចាប់យកភាសារបស់ក្មេងគឺត្រឹមអាយុ ១២ ឬ ១៣ឆ្នាំប៉ុណ្ណោះ មានន័យថា ប្រសិនបើកុមារធំធាត់ក្នុងបរិស្ថានមួយដែលកុមារមិនអាចទទួលបានការបង្ហាត់បង្រៀនផ្នែកភាសាបានសមស្របនៅដើមកុមារភាពទេ នោះនឹងកាន់តែពិបាកសម្រាប់កុមារដើម្បីចាប់យកជំនាញភាសាបន្ទាប់ពីឈានចូលដល់វ័យជំទង់។

**អំឡុងពេលវេទនារម្មណ៍ (Sensitive Period)** គឺនៅពេលដែលកុមារមានភាពរសេបំផុតទៅនឹងការរំញោចពីបរិស្ថានជាក់លាក់ណាមួយដែលមានប្រសិទ្ធភាពក្នុងការចាប់យកលំនាំថ្មីនៃអាកប្បកិរិយាដែលមានន័យថា អំឡុងពេលនេះគឺសមស្របបំផុតសម្រាប់ការចាប់យកអាកប្បកិរិយា ឬជំនាញនោះ។ ឧទាហរណ៍ បណ្ឌិតម៉ារីយ៉ាម៉ុនតេស្សូរី (Maria Montessori) (ពិពណ៌នាដោយសមាគមម៉ុនតេស្សូរីអាមេរិកថា «ក្នុងនាមជារូបវិទូជនជាតិអ៊ីតាលី ជាអ្នកអប់រំ និងជាអ្នកច្នៃប្រឌិត បានទទួលការសាទរអំពីវិធីសាស្ត្រអប់រំរបស់លោកស្រីដែលកសាងតាមវិធីដែលកុមារសិក្សាតាមបែបធម្មជាតិ») បានគាំទ្រថា អំឡុងពេលវេទនារម្មណ៍សម្រាប់ទទួលយកជំនាញយល់ដឹង និងទិដ្ឋភាពសង្គមអំពីជីវិតគឺចាប់តាំងពីទារកភាពរហូតដល់ដើមកុមារភាព។[6,7]

ទោះបីជាមាគ៌ានៃការលូតលាស់ និងការអភិវឌ្ឍរបស់បុគ្គលមិនអាចកំណត់បានពេញលេញដោយលក្ខណៈជីវសាស្ត្រក៏ដោយ ក៏យើងមិនបានទទួលការអនុគ្រោះដោយគ្មានដែនកំណត់ ខណៈដែលយើងលូតលាស់នោះដែរ។ តាមពិតការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្សស្ថិតនៅចន្លោះកត្តាទាំងពីរដែលកំណត់ដោយឥទ្ធិពលនៃលក្ខណៈជីវសាស្ត្រ និងបរិស្ថានលូតលាស់។

## ២.៥. ការលូតលាស់របស់បុគ្គលម្នាក់ៗកាន់តែមានការប្រែប្រួលខ្លាំងទៅតាមវ័យ

ការប្រែប្រួលផ្នែកជីវសាស្ត្ររបស់ទារកទើបកើតមានកម្រិតតិចតួច ប៉ុន្តែនៅពេលទារកកាន់តែចម្រើនវ័យ ការប្រែប្រួលរបស់បុគ្គលម្នាក់ៗកាន់តែមានគម្លាតធំតាមរយៈឥទ្ធិពលនៃកត្តាតំណពូជ និងបរិស្ថានលូតលាស់ (**ភាពខុសគ្នារវាងបុគ្គលម្នាក់ៗ**)។

## ៣ អំឡុងពេលនៃការលូតលាស់ និងការអភិវឌ្ឍទៅតាមវ័យ

អំឡុងពេលនៃការលូតលាស់ និងការអភិវឌ្ឍរបស់មនុស្សអាចបែងចែកទៅតាមក្រុមអាយុ៖ ទារកទើបកើត (ចាប់ពីកំណើតដល់ត្រឹមអាយុ ៤សប្ដាហ៍) ទារក (រហូតដល់អាយុ ១ឆ្នាំ) ដើមកុមារភាព (រហូតដល់ពេលចូលរៀនបឋមសិក្សា) ដែលចែកចេញជាពីរគឺ ក្មេងទើបចេះដើរ (អាយុពី ១-៣ឆ្នាំ) និងកុមារវ័យចូលរៀនមត្តេយ្យសិក្សា (អាយុពី ៣-៦ឆ្នាំ) ពាក់កណ្ដាលកុមារភាព (អំឡុងពេលចុះឈ្មោះចូលរៀនបឋមសិក្សា អាយុពី ៦-១២ឆ្នាំ) និងវ័យជំទង់ (ចាប់ពីមធ្យមសិក្សារហូតដល់ពេញវ័យ ឬរហូតដល់ឈប់លូតកម្ពស់ អាយុប្រហែលពី ១២-១៨ឆ្នាំ) (**រូបទី ៣.៣**)។ នៅទីនេះ យើងនឹងអង្កេតលម្អិតពីការលូតលាស់កាយសម្បទា ចលករ និងការអភិវឌ្ឍពុទ្ធិ ព្រមទាំងការអភិវឌ្ឍផ្នែកសតិអារម្មណ៍ និងផ្នែកសង្គមនាអំឡុងពេលដើម និងពាក់កណ្ដាលកុមារភាព (**តារាងទី ៣.១**)។




**រូបទី ៣.៣៖** ការលូតលាស់ និងការអភិវឌ្ឍអំឡុងពេលដើមកុមារភាព

### ៣.១. ការលូតលាស់ និងការអភិវឌ្ឍអំឡុងពេលដើមកុមារភាព

#### ៣.១.១. ការលូតលាស់កាយសម្បទា (Physical growth)

កម្ពស់ និងទម្ងន់រាងកាយកើនឡើងសន្សឹមៗក្នុងអំឡុងពេលនេះ។ លុះដល់កុមារមានអាយុ ៥ឆ្នាំ កម្ពស់នឹងកើនឡើង ២,២ដង ឯទម្ងន់នឹងកើនឡើង ៦ដង ធៀបជាមួយនឹងកំណើត។ រូបរាងកាយប្រែជាតូចស្ដើងជាងមុនវិវឌ្ឍទៅរូបរាងមនុស្សពេញវ័យ ហើយអនុបាតរវាងក្បាល និងដងខ្លួនឈានដល់ ១:៦ នៅអាយុ ៦ឆ្នាំ។ ធ្មេញអចិន្ត្រៃយ៍ ឬធ្មេញស្រុករបស់កុមារចាប់ផ្ដើមលូតលាស់ក្នុងអំឡុងពេលនេះជាមួយនឹងការប្រែប្រួលផ្នែកផ្សេងៗទៀតនៃរាងកាយរបស់បុគ្គល។

### ៣.១.២. ការអភិវឌ្ឍនៃមុខងារចលករ

**ការអភិវឌ្ឍជំនាញចលករធំ (Gross motor skills development)៖** ជាទូទៅកុមារចាប់ផ្ដើមរៀនដើរនៅអំឡុងអាយុ ១២ខែបន្ទាប់ពីកំណើត អាចដើរនឹងបានត្រឹមអាយុ ១៨ខែ ហើយត្រឹមអាយុ ៣ឆ្នាំ អាចលោត និងទាត់បាល់បាន។ នៅអាយុពី ៥-៦ឆ្នាំ កុមារភាគច្រើនអាចប្រើដៃ និងជើងធ្វើចលនាស៊ាំញ៉ាំ និងត្រូវចង្វាក់គ្នាបាន ដូចជា ការឈរជើងមួយ ការលោតរំលងដោយជើងទាំងពីរ និងការលោតអន្ទាក់ជាដើម។

**ការអភិវឌ្ឍជំនាញចលករតូច (Fine motor skills development)៖** កុមារចាប់ពីអាយុ ១២-១៨ខែ ជាទូទៅស្ទាត់ជំនាញជំនាញមូលដ្ឋានដូចជា ការឈោងទៅរកវត្ថុអ្វីមួយ ការចាប់កាន់ និងការពន្លែងវត្ថុនោះវិញ។ កាលដែលកុមារកាន់តែចម្រើនវ័យ ពួកគេមានសមត្ថភាពធ្វើចលនាត្រូវចង្វាក់គ្នាក្នុងការប្រើឧបករណ៍នានាដោយដៃទាំងពីរ។ អាយុចាប់ពី ៣-៤ឆ្នាំ ពួកគេអាចប្រើកន្ត្រៃ ឬដោះឡេវ និងដាក់ឡេវសម្លៀកបំពាក់បានដែលចលនានេះតម្រូវឱ្យមានចលនាឆ្លាស់គ្នារវាងដៃទាំងពីរ ប៉ុន្តែនៅក្នុងឥរិយាបថឆ្គងនៅឡើយ។ ចាប់ពីអាយុប្រហែល ៤ឆ្នាំ ក្មេងចាប់ផ្ដើមបង្ហាញពីទំនោរក្នុងការប្រើប្រាស់ដៃដែលចំណាប់ជាងគេជាប្រចាំ។ នៅត្រឹមអាយុ ៥-៦ឆ្នាំ ពួកគេមានសមត្ថភាពធ្វើចលនាសន្លាក់ម្រាមដៃយ៉ាងប៉ិនប្រសប់មានន័យថា ពួកគេអាចរៀនសរសេរអក្សរដោយរំកិលប៊ិចដោយប្រើចុងមេដៃ ម្រាមដៃចង្អុល និងម្រាមដៃកណ្ដាល។ ពួកគេអាចកាន់កែវក្រដាសដោយមិនធ្វើឱ្យកែវនោះខូចទ្រង់ទ្រាយដោយប្រើប្រាស់កម្លាំងសមល្មមទៅនឹងភាពធន់របស់វត្ថុនោះ។

### ៣.១.៣. ការអភិវឌ្ឍពុទ្ធិ (Cognitive development)

កុមារនៅអាយុពី ២-៣ឆ្នាំ ចាប់ផ្ដើមអភិវឌ្ឍការគិតបែបអរូបី មានសមត្ថភាពបង្កើតរូបភាពអ្វីមួយតាមរយៈបទពិសោធន៍ដែលធ្លាប់ឃើញ និងស្រមៃពីវត្ថុនានាដែលមិនធ្លាប់ឃើញដោយផ្ទាល់ពីមុនមក។ ពេលដែលពួកគេឈានដល់អាយុ ៤-៦ឆ្នាំ ពួកគេមានសមត្ថភាពអាចបែងចែកក្រុមវត្ថុនានាដោយឡែកៗពីគ្នា និងផ្គុំវាចូលគ្នាវិញបាន។ ពួកគេក៏ស្គាល់ឆ្វេង និងស្ដាំដោយយោងទៅតាមរាងកាយរបស់ពួកគេផ្ទាល់។ នៅពេលគូររូបមនុស្ស ពួកគេចាប់ផ្ដើមគូរដៃ និងជើង ទោះបីជាគ្មានលក្ខណៈលម្អិតគ្រប់គ្រាន់ក៏ដោយ។

ការអភិវឌ្ឍផ្នែកភាសាមានសន្ទុះខ្លាំងនៅអំឡុងពេលរៀនដើរនេះ។ បន្ទាប់ពីអាយុ ១៨ខែ-២ឆ្នាំ បន្ទាប់ពីកំណើត កុមារចាប់ផ្ដើមអាចផ្គុំពីរពាក្យក្នុងមួយប្រយោគ ហើយវាក្យស័ព្ទរបស់ពួកគេរីកចម្រើនយ៉ាងរហ័ស។ គេអាចនិយាយបានថា ត្រឹមអាយុ ២ឆ្នាំ កុមារជាទូទៅចេះវាក្យស័ព្ទលើសពី ៣០០ពាក្យ។ ចាប់ពីអាយុ ៤-៦ឆ្នាំ (វ័យចូលរៀនមត្តេយ្យសិក្សា) ពួកគេយល់ពាក្យ «ឆ្មា» គឺជា «សត្វ» និងពាក្យ «ចេក» គឺជា «អាហារ»។ នេះមានន័យថា ពួកគេយល់ពីនិយមន័យពាក្យទាំងនោះ និងអាចចាត់ថ្នាក់ពាក្យដែលតំណាងវត្ថុរូបីទៅក្នុងថ្នាក់របស់ន័យអរូបីបាន។

### ៣.១.៤. ការអភិវឌ្ឍផ្នែកសតិអារម្មណ៍ និងផ្នែកសង្គម (Emotional and social development)

ការអភិវឌ្ឍផ្នែកសតិអារម្មណ៍ និងផ្នែកសង្គមក្នុងអំឡុងពេលដើមកុមារភាពផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងទំនាក់ទំនងរបស់មនុស្ស ទម្លាប់របៀបរស់នៅមូលដ្ឋាន និងការលេងកំសាន្តដែលកុមារបានឆ្លងកាត់។ កុមារចាប់ផ្ដើមអភិវឌ្ឍភាពម្ចាស់ការលើខ្លួនឯង និងបង្ហាញពីសេចក្ដីប្រាថ្នារបស់គេ។ ឧទាហរណ៍ កុមារអាយុពី ២-៣ឆ្នាំ ចេះលេងដោយខ្លួនឯង ធ្វើអ្វីដោយខ្លួនឯង ទោះបីជាមានមនុស្សនៅជុំវិញខ្លួនក៏ដោយ ប៉ុន្តែនៅពេលចម្រើនវ័យឡើង ពួកគេចាប់ផ្ដើមបន្តិចម្ដងៗរៀនលេងជាមួយមនុស្សដទៃផ្សេងទៀតដែលនៅជុំវិញ។ នៅពេលពួកគេមានអាយុពី ៥-៦ឆ្នាំ ពួកគេអាចចែករំលែកគោលបំណង និងលក្ខន្តិកៈសាមញ្ញៗខណៈពេលកំពុងលេង។ ពួកគេអភិវឌ្ឍសមត្ថភាពយល់ដឹងអំពីអារម្មណ៍អ្នកដទៃនៅអាយុប្រហែល ៤ឆ្នាំ ហើយមានសមត្ថភាពគិតពិចារណាដោយមើលពីជ្រុងគំនិតមួយផ្សេងទៀតរបស់មនុស្សដទៃ។

## ៣.២. ការលូតលាស់ និងការអភិវឌ្ឍអំឡុងពេលពាក់កណ្តាលកុមារភាព

### ៣.២.១. ការលូតលាស់ និងការអភិវឌ្ឍកាយសម្បទា

ការលូតលាស់ និងការអភិវឌ្ឍកាយសម្បទាគឺមានស្ថិរភាព និងសន្សឹមៗនៅអំឡុងពេលពាក់កណ្តាលខាងដើមនៃអំឡុងពេលពាក់កណ្តាលកុមារភាព។ កាលណាកុមារឈានចូលដល់ពាក់កណ្តាលខាងចុងនៃអំឡុងពេលពាក់កណ្តាលកុមារភាព មុខងារបន្តពូជអភិវឌ្ឍយ៉ាងឆាប់រហ័សជាមួយការប្រែប្រួលខ្លះៗរបស់បុគ្គល។ ប្រដាប់បន្តពូជក្មេងស្រីលូតលាស់លឿនជាងក្មេងប្រុស។ ក្មេងស្រីចាប់ផ្តើមមានដើមទ្រូងរីកធំ និងមានដុះរោមនៅប្រដាប់បន្តពូជ។

### ៣.២.២. ការអភិវឌ្ឍចលករ

កុមារលូតលាស់សាច់ដុំ និងចាប់យកជំនាញចលករមូលដ្ឋាននៅអំឡុងពេលពាក់កណ្តាលកុមារភាព។ ពួកគេអាចលោត បោះ និងធ្វើចលនានានាបានជំនាញជាងពេលនៅអំឡុងពេលដើមកុមារភាព។ ពួកគេរៀនផ្សំធ្វើចលនាមូលដ្ឋានងាយៗដោយប្រើដៃនិងជើង និងទទួលបានជំនាញធ្វើចលនាតាមកាលវេលាទីតាំងជាក់ស្តែង។

### ៣.២.៣. ការអភិវឌ្ឍពុទ្ធិ

ក្នុងទស្សនវិស័យនៃការយល់ដឹង កុមារចាប់ផ្តើមគិតបានត្រឹមត្រូវអំពីបញ្ហាជាក់លាក់នានា។ នៅពេលអាយុពី ៩-១០ឆ្នាំ ពួកគេអាចសម្គាល់នូវបរិមាណស្មើគ្នានៃសារជាតិមួយ បើទោះជាគេដាក់វាក្នុងវត្ថុផ្ទុកខុសៗគ្នាក៏ដោយ។ ទាំងនេះបង្ហាញថា ពួកគេមានសមត្ថភាពក្នុងការប្រៀបធៀបអំពីគោលគំនិតមួយ និងបានយល់ជាស្រេចចំពោះគោលគំនិតទាំងនោះដូចជា ចំនួន ទម្ងន់ ចំណុះ និងម៉ោង។ អាយុចន្លោះពី ១១-១២ឆ្នាំ កុមារចាប់ផ្តើមគិតជាប្រព័ន្ធ និងធ្វើការសន្និដ្ឋានលទ្ធផលដោយផ្អែកលើសម្មតិកម្ម។ ទម្រង់ប្រាស្រ័យទាក់ទងចម្បងរបស់កុមារគឺការនិយាយអំឡុងពេលពាក់កណ្តាលកុមារភាព ប៉ុន្តែពេលគេចម្រើនវ័យ និងចូលរៀន ពួកគេចាប់យកការប្រាស្រ័យទាក់ទងក្រោមទម្រង់ផ្សេងទៀតដូចជា ការសរសេរ និងការអាន។ នៅអំឡុងពេលពាក់កណ្តាលខាងដើមនៃអំឡុងពេលពាក់កណ្តាលកុមារភាព កុមារមានទំនោរសរសេរប្រយោគខ្លីៗតែប៉ុណ្ណោះ ប៉ុន្តែពួកគេនឹងសរសេរប្រយោគកាន់តែវែងជាងមុនដោយប្រើសទ្ទានសព្ទនៅពាក់កណ្តាលខាងចុងនៃអំឡុងពេលពាក់កណ្តាលកុមារភាពនេះ។

### ៣.២.៤. ការអភិវឌ្ឍផ្នែកសតិអារម្មណ៍ និងផ្នែកសង្គម

អំឡុងពេលពាក់កណ្តាលកុមារភាពគឺជាពេលវេលាមួយដែលកុមារអភិវឌ្ឍអារម្មណ៍ផ្នែកសង្គមដូចជា ដឹងពីខ្លួនឯង និងការយោគយល់គ្នានៅក្នុងក្របខ័ណ្ឌសង្គមរបស់សាលារៀន។ សតិសម្បជញ្ញៈអាចសម្គាល់ឃើញតាំងពីអំឡុងពេលដើមកុមារភាពម្ល៉េះ ប៉ុន្តែកុមារចាប់ផ្តើមស្គាល់ និងដឹងពីខ្លួនឯងជាជីវិតមួយ (ឧទាហរណ៍ ឆ្លងកាត់បទពិសោធន៍ដឹងពីវត្តមានជីវិតរបស់ខ្លួនឯង) តាមរយៈទំនាក់ទំនងក្នុងសង្គមជាមួយមិត្តភក្តិរបស់ពួកគេ នៅពេលដែលពួកគេចូលដល់អំឡុងពេលពាក់កណ្តាលកុមារភាព។ ពួកគេអភិវឌ្ឍអារម្មណ៍ពីសមត្ថភាពក៏ដូចជាភាពអន់ជាង តាមរយៈការប្រៀបធៀបជាមួយអ្នកដទៃ ហើយបន្តិចម្តងៗបង្កើតអារម្មណ៍ចេះឱ្យតម្លៃខ្លួនឯង (self-esteem)។ ទំនាក់ទំនងមិត្តភក្តិពីម្នាក់ទៅម្នាក់ (Peer-to-peer relationships) ក៏អាចធ្វើឱ្យមានការប្រែប្រួលនៅពាក់កណ្តាលខាងចុងនៃអំឡុងពេលពាក់កណ្តាលកុមារភាពផងដែរ។ ក្រុមមិត្តភក្តិដែលកុមារម្នាក់ៗសេពគប់កាន់តែរីកធំៗឡើង។ កុមារៗបង្កើតក្រុមអាស្រ័យលើអារម្មណ៍សាមគ្គីដោយការលេងជាមួយគ្នា និងការចែករំលែកបទពិសោធន៍រួម។ អំឡុងពេលនេះហៅថា «វ័យទំនើង (gang age)» ហើយក្រុមមិត្តភក្តិទាំងនោះព្រមទទួលយកផ្ទត់សង្គមនេះដូចគ្នា។ ជានិច្ចកាលក្រុមទំនើង ឬក្រុមមិត្តភក្តិទាំងនេះ ភាគច្រើនជាចរិតលក្ខណៈជាក្រុមក្មេងប្រុស។

**តារាងទី ៣.១៖ សង្ខេបពីសូចនាករនៃការអភិវឌ្ឍនៅអំឡុងពេលដើម និងអំឡុងពេលពាក់កណ្ដាលកុមារភាព**

| ខ្នាតនៃការ អភិវឌ្ឍ | ទារកភាព និងអំឡុងពេលដើមកុមារភាព | | | | | អំឡុងពេល ពាក់កណ្ដាលកុមារភាព | |
|---|---|---|---|---|---|---|---|
| អាយុ | 0 - 1 | 1 - 2 | 2 - 3 | 3 - 4 | 4 - 5 | 5 - 6 | 6 - 7 |
| កម្ពស់ | 1,5ដង កម្ពស់កំណើត | | | 2ដង កម្ពស់កំណើត | | | |
| ទម្ងន់ | 3ដង ទម្ងន់កំណើត | 4ដង ទម្ងន់កំណើត | | 5ដង ទម្ងន់កំណើត | | | |
| ជំនាញចលករធំ | ឈរកាន់គ្រឿងសង្ហារិម | ដើរ | រត់ | | | | |
| | ទំលាក់បាល់ និងតាមសម្លឹងមើលវា | បោះបាល់សំដៅគោលដៅ | ទាត់បាល់ | លោតជើងមួយ | លោតជើងពីរ | ចេះចាប់បាល់ដោយប្រើដៃទាំងពីរ | |
| ជំនាញចលករតូច | | គូរ និងចម្លងរាងជាខ្សែៗ | គូររាងរង្វង់មួយ | គូររាងការេ | គូររាងត្រីកោណ | | |
| | | សាងសង់ដោយប្រើដុំវត្ថុរាងបួនជ្រុង (blocks) | | ចេះប្រើកន្ត្រៃ | | | |
| ជំនាញភាសា | បង្កើតពាក្យងាយយល់ជាលើកដំបូង | បង្កើនវាក្យស័ព្ទ | សួរដោយប្រើប្រយោគសំណួរ | | | អាចធ្វើការសន្ទនាទៅវិញទៅមកបាន | អាន សរសេរ និងចាប់យកជំនាញសិក្សាមូលដ្ឋានបាន |
| ជំនាញចិត្ត និងសង្គម | យល់ និងគោរពតាមបម្រាម | លេងម្នាក់ឯងក្រៅពីជាមួយឪពុកម្ដាយបាន | លេងជាមួយមិត្តភក្តិ | លេងជាមួយក្រុមគ្នាបីនាក់ ឬច្រើននាក់ | | ការគិតសមហេតុផល និងតាមទ្រឹស្ដី | អាចធ្វើការពិចារណាក្នុងចិត្ត |
| | ប្រព្រឹត្តសារឡើងវិញពេលមានការសរសើរ | ធ្វើត្រាប់តាមការសន្ទនាតាមទូរស័ព្ទ | ចូលចិត្តមើលថែក្មេងៗដែលតូចជាង | សុំការអនុញ្ញាត | | អាចប្ដូរការគិតពីរូបីទៅអរូបី | |

## ៤ កត្តានានាដែលមានឥទ្ធិពលចំពោះការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ

តាមសាវតារកន្លងមក សុខភាពកុមារត្រូវបានកំណត់ដូចសុខភាពមនុស្សពេញវ័យដែរ និងស្ទើរតែមិនបានទទួលការយកចិត្តទុកដាក់ជាពិសេសសោះតែម្តង។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះគេបានទទួលស្គាល់ថា ទស្សនវិស័យនៃការអភិវឌ្ឍចាំបាច់ត្រូវរួមបញ្ចូលទៅក្នុងបញ្ញត្តិសុខភាពកុមារ។ វាកាន់តែច្បាស់ហើយថា សុខភាពកុមារត្រូវបានកំណត់តាមរយៈអន្តរកម្មនៃកត្តានានាជាច្រើនខុសគ្នាពីមនុស្សពេញវ័យ។ ផ្ទុយពីសាវតារនេះ គណៈកម្មការវាយតម្លៃសុខភាពកុមារ (ក្រុមប្រឹក្សាជាតិស្រាវជ្រាវ និងវិទ្យាស្ថានវេជ្ជសាស្ត្រនៃប្រទេសសហរដ្ឋអាមេរិក) បានចេញរបាយការណ៍មួយស្នើឱ្យមានការកំណត់បញ្ញត្តិនៃសុខភាពកុមារដូចខាងក្រោមដើម្បីបញ្ចូលការលូតលាស់ និងការអភិវឌ្ឍ ព្រមទាំងបង្ហាញផ្លូវពីកត្តាផ្សេងៗដែលមានឥទ្ធិពលលើសុខភាពក្នុងការអភិវឌ្ឍ។[8]

«សុខភាពកុមារគឺជាវិសាលភាពដែលកុមារម្នាក់ៗ ឬក្រុមកុមារច្រើនអាចធ្វើបាន ឬជួយឱ្យធ្វើបានដើម្បី (ក) អភិវឌ្ឍ និងសម្រេចបាននូវសក្តានុពលរបស់គេ (ខ) បំពេញចិត្តនូវតម្រូវការរបស់គេ និង (គ) អភិវឌ្ឍសមត្ថភាពដែលអនុញ្ញាតឱ្យពួកគេមានទំនាក់ទំនងដោយជោគជ័យជាមួយបរិស្ថានជីវសាស្ត្រ រូបវន្ត និងសង្គមរបស់ពួកគេ»។[8]

**តារាងទី ៣.២៖ ប្រព័ន្ធឥទ្ធិពលដែលមានលើសុខភាពកុមារ**

**ជីវសាស្ត្រកុមារ**
**អាកប្បកិរិយាកុមារ**
**បរិស្ថានរូបវន្ត**
- ឥទ្ធិពលពីមុនកំណើត
- ឥទ្ធិពលពីកុមារភាព
- ផ្ទះ សាលារៀន និងកន្លែងធ្វើការ
- របួសកុមារ និងការផ្តល់បរិស្ថានមានសុវត្ថិភាព
- សំណង់បរិស្ថាន

**បរិស្ថានសង្គម**
- គ្រួសារ
- សហគមន៍
- វប្បធម៌
- ការរើសអើង

**សេវា**
- គោលនយោបាយ

***ដកស្រង់ពី៖*** *«គណៈកម្មការវាយតម្លៃសុខភាពកុមារ។ សុខភាពកុមារ ទ្រព្យសម្បត្តិជាតិ៖ ការវាយតម្លៃ និងកែលម្អសុខភាពកុមារ»* [9]
*«(Committee on Evaluation of Children's Health. Children's health, the nation's wealth: Assessing and improving child health.)»* [9]

យោងតាមរបាយការណ៍ វាមានកត្តាជីវសាស្ត្រ អាកប្បកិរិយា និងបរិស្ថាន (រូបវន្ត និងសង្គម) ដែលមានឥទ្ធិពលលើសុខភាពនៃការអភិវឌ្ឍរបស់កុមារ (**តារាងទី ៣.២**)។ តាមរយៈរបាយការណ៍នេះ យើងអាចយល់ពីកត្តាជាច្រើនដែលមានឥទ្ធិពលលើសុខភាពកុមារ។ **ឥទ្ធិពលផ្នែកជីវសាស្ត្រ (Biological influences)** រួមមាន ការបង្ហាញរបស់សែន ឥទ្ធិពលពីមុនកំណើត ព្រមទាំងព្រឹត្តិការណ៍នានាមុន និងក្រោយកំណើត។ **ឥទ្ធិពលអាកប្បកិរិយា (Behavioral influences)** រួមមាន អារម្មណ៍ ជំនឿ ឥរិយាបថ អាកប្បកិរិយា និងសមត្ថភាពពុទ្ធិរបស់កុមារ។ **ឥទ្ធិពលបរិស្ថាន (Environmental influences)** មានភាពទូលំទូលាយរួមមាន ឥទ្ធិពលពីបរិស្ថានជីវសាស្ត្រ (ឧទាហរណ៍ ភ្នាក់ងារបង្ករោគជំងឺគ្រុនចាញ់ និងព្រូនពោះវៀននៅប្រទេសកម្ពុជា) និងបរិស្ថានរូបវន្ត (ឧទាហរណ៍ ទឹកកខ្វក់ និងការប៉ះពាល់លោហៈធាតុ និងថ្នាំសម្លាប់សត្វល្អិតនៅប្រទេសកម្ពុជា) និងកត្តាសង្គមនានាដូចជា ទំនាក់ទំនងទឹកចិត្តស្រលាញ់រវាងបុគ្គលនឹងអាណាព្យាបាល (ឧទាហរណ៍ អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន និងសុខភាពផ្លូវចិត្តមាតានៅប្រទេស

កម្ពុជា) ធនធានសេដ្ឋកិច្ចសង្គមនៅក្នុងគ្រួសារ និងសហគមន៍ (ឧទាហរណ៍ ប្រាក់ចំណូល និងឱកាសការងារនៅប្រទេសកម្ពុជា) និងទំនាក់ទំនងមិត្តភក្តិ ព្រមទាំងភាពដែលអាចរកបាន និងគុណភាពនៃសេវានានា (ឧទាហរណ៍ សេវាសុខាភិបាលនៅប្រទេសកម្ពុជា)។[9]

នៅក្នុងការស្ទង់មតិមួយអំពីកត្តានានាដែលប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍនៃដើមកុមារភាពផ្អែកលើស្ថានភាពបច្ចុប្បន្ននៅប្រទេសប៊ូតាន គេបានកំណត់កត្តាចម្បងប្រាំដែលរួមចំណែកដល់ការលូតលាស់ និងការអភិវឌ្ឍនៃដើមកុមារភាព៖ អាហារូបត្ថម្ភ បរិស្ថាន អាកប្បកិរិយារបស់ឪពុកម្ដាយ ការចិញ្ចឹមថែទាំកូន និងការប្រតិបត្តិផ្អែកសង្គម និងវប្បធម៌។[10] **តារាងទី ៣.៣** បង្ហាញពីកត្តាប្រឈមនានាចំពោះភាពយឺតយ៉ាវនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលរៀបរាប់ឥទ្ធិពលពីកត្តាទាំងសងខាងគឺ កត្តាសហគមន៍ ឬកត្តាអេកូសាស្ត្រ និងកត្តាបុគ្គលមកលើកុមារវ័យចូលរៀនមត្តេយ្យសិក្សា។[11]

បញ្ហាការលូតលាស់ និងការអភិវឌ្ឍរបស់កុមារប្រកបដោយសុខភាពល្អគឺជាការយកចិត្តទុកដាក់ស្នូលនៃប្រទេសកម្ពុជាផងដែរ។ ស្ថានភាពសុខភាពកុមារនៅប្រទេសកម្ពុជាមានភាពប្រសើរច្រើនចាប់ពីឆ្នាំ ២០០០-២០១០៖ អត្រាស្លាប់របស់ទារក (ចំនួនស្លាប់ក្នុងកំណើតរស់ ១ ០០០នាក់) បានធ្លាក់ចុះពី ៩៥ មកត្រឹម ៤៥ ហើយការស្លាប់របស់កុមារអាយុក្រោមប្រាំឆ្នាំ (ចំនួនស្លាប់ក្នុងកំណើតរស់ ១ ០០០នាក់) បានធ្លាក់ចុះពី ១២៤ មកត្រឹម ៥៤ វិញ។[12] ម្យ៉ាងវិញទៀត ស្របជាមួយកត្តាប្រឈមនានាបង្ហាញក្នុង**តារាងទី ៣.៣** និងការសិក្សានៅប្រទេសប៊ូតានបានបង្ហាញថា បញ្ហាប្រឈមនៅតែមានដែលចាំបាច់ត្រូវដោះស្រាយដូចជា ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភ លក្ខខណ្ឌអនាម័យដូចជា ប្រភពទឹកនិងបរិក្ខារបង្គន់អនាម័យ ការប្រឆាំងអំពើហិង្សា និងពលកម្មកុមារ ព្រមទាំងវិសមភាពសេដ្ឋកិច្ចសង្គមរវាងគ្រួសារនៅជនបទ និងទីក្រុង។ ដូច្នេះ ដើម្បីលើកកម្ពស់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារកម្ពុជាប្រកបដោយសុខភាពល្អ វាចាំបាច់ត្រូវតែបង្ហាញឱ្យច្បាស់ពីកត្តាប្រឈម និងកត្តាជំរុញនានាដល់ការលូតលាស់និងការអភិវឌ្ឍដោយគម្រង់ចំពោះចន្លោះគម្លាតអាយុធំ និងសង្កត់ធ្ងន់ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះដោយផ្តួចផ្តើមតាមសុខភាពសិក្សាក្រោមគោលនយោបាយថ្នាក់ជាតិ។

**តារាងទី ៣.៣៖ ឧទាហរណ៍នៃកត្តាហានិភ័យសហគមន៍ ឬអេកូសាស្ត្រ និងកត្តាហានិភ័យបុគ្គលក្នុងចំណោមកុមារវ័យចូលរៀនមត្តេយ្យសិក្សានៅប្រទេសកំពុងអភិវឌ្ឍន៍នានា**

| កត្តាហានិភ័យសហគមន៍ ឬអេកូសាស្ត្រ | កត្តាហានិភ័យបុគ្គល |
|---|---|
| - ខ្សត់អនាម័យ | - ការបង្ករោគដដែលៗឡើងវិញ |
| - ទុរ្ភិក្ស | - កង្វះអាហារូបត្ថម្ភ |
| - ហិង្សាក្នុងតំបន់ | - ការបំពាន និងការបោះបង់ចោលមិនយកចិត្តទុកដាក់ |
| - ខ្វះខាតសេវាដែលអាចប្រើប្រាស់បាន៖ | - ចំណូលគ្រួសារទាបខ្លាំង |
| - សាលាមត្តេយ្យ សាលារៀន បណ្ណាល័យ សេវាសុខាភិបាល | - កើតមិនគ្រប់ទម្ងន់ |
| - ខ្វះឆន្ទៈដើម្បីអភិវឌ្ឍកុមារ | - ម្ដាយមានការអប់រំទាប |
| | - គ្រួសារមានកូនច្រើន |
| | - កូនញឹក |
| | - ការលើកកម្ពស់ការអនុវត្តថែទាំចិញ្ចឹមកូននៅមានកម្រិតទាប |

***ដកស្រង់ពី៖** «ការពិនិត្យឡើងវិញកត្តាហានិភ័យចំពោះការលូតលាស់និងការអភិវឌ្ឍយឺតយ៉ាវក្នុងចំណោមកុមារវ័យចូលរៀនមត្តេយ្យសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍន៍»*[11]

*"A brief review of risk-factors for growth and developmental delay among preschool children in developing countries"*[11]

ពិចារណាចំពោះស្ថានភាពនេះ រដ្ឋាភិបាលកម្ពុជាបានអភិវឌ្ឍផែនការសកម្មភាពជាតិប្រាំឆ្នាំ ស្តីពីការថែទាំ និងការអភិវឌ្ឍចំពោះដើមកុមារភាព ឆ្នាំ ២០១៤-២០១៨ ជាអាទិភាព ក្នុងគោលបំណងដើម្បីបង្កើនអត្រាចុះឈ្មោះចូលរៀន និងលើកកម្ពស់ការការពារកុមារទាំងអស់ដែលមានអាយុក្រោម ៦ឆ្នាំ ជាពិសេសកុមារមកពីគ្រួសារក្រីក្រ និងក្រុមជនជាតិដើមភាគតិច ព្រមទាំងកុមារពិការដែលជាក្រុមងាយនឹងបាត់បង់ឱកាសសិក្សាដំបូងជាងគេបំផុត។ តាមរយៈផែនការសកម្មភាពនេះ រដ្ឋាភិបាលកម្ពុជាប្តេជ្ញាពង្រីកការគាំទ្រ និងកែលម្អគុណភាពនៃការអភិវឌ្ឍនិងថែទាំកុមារតូចនៅទូទាំងប្រទេស។[13]

## ☞ លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម

[៣-១] ចូរគិតអំពីកុមារម្នាក់ដែលអ្នកស្គាល់ (ប្អូនប្រុស ឬប្អូនស្រី កុមារក្នុងតំបន់រស់នៅរបស់អ្នក ។ល។) ហើយពិនិត្យពីស្ថានភាពនៃការលូតលាស់និងការអភិវឌ្ឍរបស់កុមារនោះ ដោយផ្អែកតាមខ្នាតនៃការអភិវឌ្ឍក្នុង**តារាងទី ៣.១**។

[៣-២] ចូរពិភាក្សាអំពីសក្តានុពលគុណប្រយោជន៍ និងសារៈសំខាន់សម្រាប់គ្រូបង្រៀនម្នាក់ក្នុងការសិក្សាអំពីដំណើរនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។

[៣-៣] ចូរពិនិត្យមើលគំរូនៃខ្សែកោងកំណើនរបស់លោក ស្កេមម៉ុន (Scammon) នៅលើអ៊ីនធឺណែត និងលក្ខណៈរបស់វា។ បន្ទាប់គិតអំពីមូលហេតុដែលភាពខុសគ្នានៃគំរូទាំងនេះកើតឡើង។

[៣-៤] ចូរគិតអំពីហេតុការណ៍ និងព្រឹត្តិការណ៍ដែលជា ឬអាចជាការគំរាមកំហែងដល់ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារនៅប្រទេសកម្ពុជា។

## ឯកសារយោង៖


1. Comp., Emiko Fukuda, “*Ningen hattatsugaku* (Human development)” 5th edition, Tokyo: Chugai-Igakusha, 2019.
2. Comp., Goro Kono and Etsujiro Takahashi, “*Hoikuno nakano hoken – Yochien/hoikusho denohokenshido no riron to jissen* (Health as part of nursing – Theory and practice of health guidance in nursery schools),” revised edition, Tokyo: Houbunshorin, 2010.
3. Ruffin N.J. Human growth and development – A matter of principles. Virginia Cooperative Extension. Virginia Tech. 2019. https://www.pubs.ext.vt.edu/content/dam/pubs_ext_vt_edu/350/350-053/350-053 (FCE-134P).pdf
4. Dhaker R. Growth and development. https://www.slideshare.net/rdhaker2011/growth-and-developmentppt
5. Schaffer H.R. Key Concepts in developmental psychology, 58-61, Los Angeles, Sage, 2006
6. Montessori M. Six “Sensitive Periods”. https://www.montessoritrainingusa.com/sites/montessoritrainingusa.com/files/Six%20Sensitive%20Periods.pdf
7. American Montessori Association. Who Was Maria Montessori? https://amshq.org/About-Montessori/History-of-Montessori/Who-Was-Maria-Montessori
8. Committee on Evaluation of Children's Health. Children's Health, the Nation's Wealth: Assessing and Improving Child Health. p.4, Washington DC, The National Academies Press, 2004. https://www.ncbi.nlm.nih.gov/books/NBK92198/#ch2.s3
9. Committee on Evaluation of Children's Health. Children's Health, the Nation's Wealth: Assessing and Improving Child Health. p.45-90, Washington DC, The National Academies Press, 2004. https://www.ncbi.nlm.nih.gov/books/NBK92200/#ch3.s1
10. Pem D. Factors Affecting Early Childhood Growth and Development: Golden 1000 Days. Journal of Advanced Practices in Nursing, 1:1, 2015. DOI:10.4172/2573-0347.1000101
11. Ali S.S. A brief review of risk-factors for growth and developmental delay among preschool children in developing countries. Advanced Biomedical Research. 2:91.2013 doi: 10.4103/2277-9175.122523
12. National Institute of Statistics, Directorate General for Health, and ICF Macro, 2011. 2010 Cambodia. Demographic and Health Survey: Key Findings. Phnom Penh, Cambodia and Calverton, Maryland, USA: National Institute of Statistics, Directorate General for Health, and ICF Macro https://www.nis.gov.kh/nis/CDHS/CDHS_2010_Key_Findings.pdf
13. The National Committee of Early Childhood Care and Development. National Action Plan on Early Childhood Care and Development 2014-2018. https://planipolis.iiep.unesco.org/sites/planipolis/files/ressources/cambodia_early_childhood_national_action_plan_2014-2018.pdf